ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះស្រុកក្រចេះ ទៅជាស្រុកចិត្របុរី និងការបង្កើតក្រុងក្រចេះ នៃខេត្តក្រចេះ

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះស្រុកក្រចេះ ទៅជា ស្រុកចិត្របុរី នៃខេត្តក្រចេះ។

**មាត្រា ២.-**

ត្រូវបានបង្កើត ក្រុងក្រចេះ នៃខេត្តក្រចេះ ដោយកាត់យកឃុំចំនួនប្រាំ គឺ ឃុំអូរឬស្សី ឃុំក្រចេះ

ឃុំកោះទ្រង់ ឃុំក្រគរ និង ឃុំរកាកណ្តាល ពីស្រុកចិត្របុរី នៃខេត្តក្រចេះ ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងក្រចេះ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំ ចំនួនប្រាំនៃ ក្រុងក្រចេះ ឱ្យទៅជាសង្កាត់ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំ អូរឫស្សី | ទៅជា | សង្កាត់អូរឫស្សី |
| ២- ឃុំ ក្រចេះ | ទៅជា | សង្កាត់ក្រចេះ |
| ៣- ឃុំ កោះទ្រង់ | ទៅជា | សង្កាត់កោះទ្រង់ |
| ៤- ឃុំ ក្រគរ | ទៅជា | សង្កាត់ក្រគរ |
| ៥-ឃុំ រកាកណ្តាល | ទៅជា | សង្កាត់រកាកណ្តាល |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកចិត្របុរី ដែលស្ថិតនៅសង្កាត់អូរឫស្សី ទៅជាសាលា ក្រុងក្រចេះ ។

**មាត្រា ៥.-**

ទីតាំងសាលាស្រុកចិត្របុរី ត្រូវស្ថិតនៅក្នុងឃុំជារ ស្រុកចិត្របុរី ខេត្តក្រចេះ ។

**មាត្រា ៦.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងក្រចេះ ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តក្រចេះ អភិបាលក្រុងក្រចេះ អភិបាលស្រុកចិត្របុរី និង ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ផែនទី ក្រុងក្រចេះ និង ស្រុកចិត្របុរី
សញ្ញាសំគាល់
ផ្លូវជាតិ
ព្រំប្រទល់ឃុំ
ទន្លេមេគង្គ
ក្រុងក្រចេះ
ស្រុកចិត្របុរី
ឃុំ ក្បាលដំរី
ឃុំ សណ្តាន់
សំបុក
ក្រគរ
អូររឫស្សី
ក្រចេះ
កន្ទួត
5,000 2,500 0 5,000
Meters
N
S
E
W